# តក្កភាព នៃ ពួក ជន ភ្លីភ្លើ

ការយក លោក កឹម សុខា ទៅ កាត់ទោស វា ជា តក្កភាព នៃ ពួក ជន ភ្លីភ្លើ[1] ដែល លែង មាន គតិ ជា មនុស្ស។ ចុះដូចម្ដេច ពួក ជន ទាំងនោះ វា ធ្វើ អំពើ បែប នេះ បាន ? មនុស្ស ភ្លើ ជា មនុស្ស មាន ស្មារតី ភ្លេចៗ ថា ខ្លួន ជា មនុស្ស ដែល គេ ប្រដូច នឹង ស្វា ពាក់ ម្កុដ គឺ ថា ស្វា ដែល គេ បំពាក់ ម្កុដ ឱ្យហើយ វា តែង ភ្លេច ខ្លួន ថា ក្បាល វា មាន ពាក់ ម្កុដ តែ កាល ណា រមាស់ ក្បាល ក៏ តាំង លើក ជើង អេះ ក្បាល ភ្លាម នាំ ឱ្យ គេ មើល យល់ ភ្លាម ថា វា ជា ស្វា ពិត ប្រាកដ។ មនុស្ស ភ្លីភ្លើ តាំង ខ្លួន ជា អ្នកដឹកនាំ ជាតិ ហើយ នាំ គ្នា ពាក់ ងារ ជា អភិជន តែ គ្រា ណា អាចនឹង លួច ជាតិ បាន ក៏ តាំង ប្រើ អំណាច ផ្ដាច់ការ ភ្លាម នាំ ឱ្យ គេ មើល យល់ ភ្លាម ថា វា ជា ចោរ ពិត ប្រាកដ។ ពួក ជន ភ្លីភ្លើ ទាំងនោះ ធ្វើ ចោរកម្ម ក្លាយ ជា ក្ដុម្ពី តែ ដោយ ភ័យ ខ្លាច បាត់ ទ្រព្យ របស់ ខ្លួន ដែល បាន មក ពី លួច គ្មាន ខ្មាស់អៀន ក៏ នាំ គ្នា ប្រឌិត ចោទ ប្រកាន់ កឹម សុខា ថា ប្រព្រឹត្ត អំពើ ក្បត់ ជាតិ ព្រោះ មាន គ្រោងការណ៍ រំលំ រដ្ឋាភិបាល។ លោក កឹម សុខា ជា នយៈជន[2] ប្រជាធិបតេយ្យ ដូច្នេះ គោលបំណង គឺ ធ្វើ តាម ច្បាប់ គ្រប់ បែបយ៉ាង ដើម្បី ឱ្យ មាន ការផ្លាស់ប្ដូរ អ្នកដឹកនាំ, សួរ ថា តើ គោលបំណង ពេញសិទ្ធិ

[1] តក្កភាព នៃ ពួក ជន ភ្លីភ្លើ : La logique des crétins។
[2] នយៈជន : អ្នកនយោបាយ។

នោះ វា ខុស អ្វី នឹង ច្បាប់ រដ្ឋធម្មនុញ្ញ ? ហើយ សកម្មភាព នយោបាយ ពេញច្បាប់ របស់ កឹម សុខា ដែល ទទួល បាន ការ គាំទ្រ ពី សំណាក់ មិត្ត អាមេរិកាំង ក្ដី ឬ បរជន ឯទៀតៗ ក្ដី ហើយ គាត់ បាន រៀនសូត្រ អំពី យុទ្ធសាស្ត្រ ប្រឆាំងនឹង អំណាច ផ្ដាច់ការ វា មាន កំហុស អ្វី ទៅ នៅ ក្នុង ក្របខណ្ឌ នៃ លទ្ធិប្រជាធិបតេយ្យ ? ឯ រឿង ដែល វា ហួស ពី ការស្មាន ទៅ ទៀត គឺ យក ការចោទប្រកាន់ សិប្បនិម្មិត លើ បុគ្គល កឹម សុខា ទៅ រំលាយ គណបក្ស សង្គ្រោះជាតិ តែ ម្ដង ដែល វា គ្មាន ចំណែង[3] អ្វី នឹង បុគ្គល ទោះបី បុគ្គល នោះ ជា ប្រធាន គណបក្ស ក៏ ដោយ។ តក្កភាព នៃ ពួក ជន ភ្លីភ្លើ ទាំងនោះ គឺ បង្ខំ ឬ ប្រចុប ឱ្យ កឹម សុខា សារភាព ដោយ ទទួល កំហុស ជា ថ្នូរ នឹង ឧបាស្រ័យអនុគ្រោះ ពី ព្រះមហាក្សត្រ ដូច ដែល ធ្លាប់ បាន ប្រព្រឹត្ត ពី មុន មក។ ដូច្នេះ រឿង នេះ វា អាស្រ័យ លើ កឹម សុខា, បើ គាត់ ចង់ បន្ត លេង ល្បែង ដូច សព្វ ដង វា គ្រាន់ តែ ទទួល ស្គាល់ កំហុស ហើយ សរសេរ លិខិត សុំ ទោស ហ៊ុន សែន ដើម្បី ឱ្យ នរៈនេះ ស្នើ ទៅ ហ្លួង ឱ្យ អនុគ្រោះ ទោស។ ដំណោះស្រាយ បែប នេះ វា បិទ ទ្វារ មិន ឱ្យ គណបក្ស សង្គ្រោះ ជាតិ ដំណើរការ បាន ឡើង វិញ នោះឡើយ។ តែ មក ដល់ ពេល នេះ កឹម សុខា គាត់ មាន គោលជំហរ បដិសេធ ទាំងស្រុង គ្រប់ ការចោទប្រកាន់ ដល់ គាត់។ កម្រាញ[4] នេះ បើ វា មាន ភាព

[3] ចំណែង : ទំនាក់ទំនង។

[4] កម្រាញ : ការមិនព្រមចុះចាញ់ ; résistance។

ម៉ឺងម៉ាត់ ជា ចិរកាល វា ច្បាស់ ជា មាន ប្រយោជន៍ ដល់ ប្រជាជាតិ ព្រោះ វា ជា ការពុះពារ នៅ ចំពោះ មុខ អំណាច ផ្តាច់ការ។ ក៏ ប៉ុន្តែ អ្វី ដែល ធ្លាប់ កើត មាន ជា រឿយៗ មកហើយ តើ វា នឹងអាច កើត មាន ឡើង វិញ ឬ ទេ ? នៅ លើ ចំណុច នេះ ឯង ដែល ខ្មែរ ភាគ ច្រើន នៅ មាន ការសង្ស័យ ដែល នាំ ឱ្យ គាត់ មាន ការមិនទុកចិត្ត ទាំងស្រុង តាម ការពិសោធ ទៅ លើ ពួក អ្នកដឹកនាំ បក្ស ប្រឆាំង ដែល តែងតែ ស្វែង រក សុខ ដល់ អាត្មា នៅ ពេល ណា ដែល ពួក គាត់ ជួប ប្រទះនឹង បញ្ហា ឬ បូកប៉ាន់ ជាមួយ ពួក ជនផ្តាច់ការ ទៅ លួម ចែក ប្រយោជន៍ គ្នា បាន ។ ពេលនេះហើយ ហើយ ប្រហែល ជា លើក ចុងក្រោយ ទៀត ផង ដែល លោក កឹម សុខា ក្តី សម រង្ស៊ី ក្តី ត្រូវ មាន ចិត្ត ខ្ពស់ ដើម្បី ប្រឈរ មុខ នឹង អំណាច ផ្តាច់ការ ដែល វា កំពុង រំអិល ដោយ ខ្លួនឯង ទៅ រក ទីបញ្ចប់ របស់ វា។ វា គ្មាន អំណាច ផ្តាច់ការ ណា មួយ អាច រស់បាន ជា អមតៈ នោះឡើយ បើ មាន ការងើប ប្រឆាំង ពី សំណាក់ ប្រជានិករ ដឹកនាំ ដោយ អ្នកតស៊ូ ប្រកប ដោយ ទឹកចិត្ត ស្នេហា ជាតិ និង ធ្វើ ពលកម្ម គ្រប់ បែប យ៉ាង ដើម្បី ប្រជាជាតិ។ កិច្ចការ ដែល ត្រូវ ធ្វើ នេះ វា មិនមែន ជា ទង្វើ ថ្មី អ្វី នោះឡើយ, វា ជា អំពើ មាន រួច ហើយ នៅ ក្នុង សតិ នៃ មនុស្សជាតិ គឺ ថា គ្រប់ ការសង្កិតសង្កិន ដល់ មនុស្ស តែងតែ មាន ការរើខ្លួន ជា និច្ច។ នេះហើយ ជា តក្កភាព នៃ មនុស្សជាតិ ប្រឆាំងនឹង តក្កភាព នៃ ពួក ជន ភ្លីភ្លើ៕